**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**
លេខ : ........៦៩.....ប.ទ.,ស.ជ.ណ.......

# សេចក្តីជូនដំណឹង
## ស្តីពី
## ការដាក់ឱ្យដំណើរការកម្មវិធីបណ្ណាល័យឌីជីថល D-Library App ( ជំនាន់ទី១ ) របស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សូមជម្រាបជូនដំណឹងដល់សាធារណជន សិស្សានុសិស្ស និស្សិត និងអ្នកស្រាវជ្រាវទាំងអស់មេត្តាជ្រាបថា ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍បានអភិវឌ្ឍ **"កម្មវិធីបណ្ណាល័យឌីជីថល D-Library App (ជំនាន់ទី១)"** រួចរាល់ហើយ និងដាក់ឱ្យដំណើរការចាប់ពីពេលនេះតទៅ។ កម្មវិធី**បណ្ណាល័យឌីជីថល D-Library App (ជំនាន់ទី១)** មានឯកសារសំខាន់ៗជាច្រើនដូចជា៖ ផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា សេដ្ឋកិច្ច កសិកម្ម ប្រវត្តិសាស្ត្រ ភូមិសាស្ត្រ នីតិសាស្ត្រ ច្បាប់ រាជកិច្ច គោលនយោបាយ វប្បធម៌សិល្បៈ សន្ទស្សន៍អន្តរជាតិ (Index) និងឯកសារដទៃទៀតដែលមានផលប្រយោជន៍សម្រាប់សិក្សាស្រាវជ្រាវ ជាពិសេសសម្រាប់សិស្សានុសិស្ស ចាប់ពីថ្នាក់ទី១ ដល់ថ្នាក់ទី១២ អាចចូលអាន និងសិក្សាដោយឥតគិតថ្លៃ ក្នុងអំឡុងនៃការរីករាលដាលនៃជំងឺកូវីដ-១៩។

លោកអ្នកអាចទាញយកកម្មវិធីនេះដោយចូលទៅកាន់ **App Store** សម្រាប់ប្រព័ន្ធប្រតិបត្តិការ **iOS** និង **Play Store** សម្រាប់ប្រព័ន្ធប្រតិបត្តិការ **Android** ហើយស្វែងរកពាក្យ **"D-Library"** រួចទាញយក និងដំឡើងកម្មវិធី **"D-Library"** នេះក្នុងទូរសព្ទដៃ ឬតាប្លេត(Tablet) របស់លោកអ្នកជាការស្រេច។ លោកអ្នកក៏អាចធ្វើការស្កេន **QR code** ខាងក្រោមដើម្បីសម្រួលដល់ការទាញយក **"D-Library"** ពី **App Store** និង **Play Store** បានផងដែរ។

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ក៏សូមធ្វើការអំពាវនាវដល់ក្រសួង ស្ថាប័ន បណ្ណាល័យ សារមន្ទីរ គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ វិស័យឯកជន និងដៃគូអភិវឌ្ឍ ចូលរួមផ្តល់ឯកសារសំខាន់ៗសម្រាប់បញ្ចូលក្នុងកម្មវិធីបណ្ណាល័យឌីជីថលនេះ ដើម្បីជាប្រយោជន៍ក្នុងការសិក្សា ស្រាវជ្រាវរបស់សិស្ស និស្សិត និងអ្នកសិក្សាស្រាវជ្រាវ តាមរយៈអ៊ីមែល **dlibrary@mptc.gov.kh** ឬទូរសព្ទលេខ **០៩៧ ៩១១ ៣៦៣៦**។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជន សិស្សានុសិស្ស និស្សិត និងអ្នកសិក្សាស្រាវជ្រាវទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងប្រើប្រាស់តាមការគួរ។

ថ្ងៃអង្គារ ៧រោច ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២១

ទាញយកកម្មវិធី

GET IT ON Google Play | Download on the App Store

អាសយដ្ឋាន : អគារលេខ ១៣ មហាវិថីព្រះមុនីវង្ស
សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
គេហទំព័រ : www.mptc.gov.kh
ទូរសព្ទ : (៨៥៥) ២៣ ៧២៤ ៨១០
ទូរសារ : (៨៥៥) ២៣ ៧២៤ ០៦៩
អ៊ីមែល : info@mptc.gov.kh